ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០២៦/១៩

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែធ្នូ ឆ្នាំ២០១៨ និងទិសដៅខែមករា ឆ្នាំ២០១៩

### I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃបានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ធ្វើការខុសច្បាប់ក្នុងប្រទេសថៃ ចាប់ពីដើមខែកក្កដា ឆ្នាំ២០១៨មក និងទោះបីរាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល៤ឆ្នាំកន្លងទៅនេះ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល។

ពលរដ្ឋខ្មែរនៅតែបាននិងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានិភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលាជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួននៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ចផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

ការអនុវត្តយុទ្ធសាស្ត្រ នៃផែនការសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១. សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់៖
    - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
    - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.២. សន្ធិសញ្ញាកំពុងរៀបចំ៖

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
    - **ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"**
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
    - **ស្តីពី "បញ្ជូនទណ្ឌិត"**
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.៣. អនុស្សរណៈកំពុងរៀបចំ៖

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រី លើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**" នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ក.៤. បទដ្ឋានគតិយុត្តិ កំពុងរៀបចំ៖

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌ ការងារកម្មករការងារផ្ទះ**"។
- **ក្រសួងអប់រំ យុវជន និងកីឡា៖** ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. កាត់បន្ថយភាពងាយរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ

រដ្ឋបាលខេត្តចំនួន៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែនថៃ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន **៨.៨២៥**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មានៈ

- ខេត្តបាត់ដំបង ចំនួន **៤.៩៣៦**ប័ណ្ណ
- ខេត្តបន្ទាយមានជ័យ ចំនួន **៣.៥៣៧**ប័ណ្ណ
- ខេត្តប៉ៃលិន ចំនួន **៣៥២**ប័ណ្ណ។

### ខ.២. ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែធ្នូ ឆ្នាំ២០១៨នេះ **ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ** មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំមានសុវត្ថិភាព"** ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន **៨.៤៧៩**លើក មានអ្នកចូលរួមសរុបចំនួន **៤៥១.៦០៣**នាក់ (ស្រី **២៤៣.៣៦៦**នាក់) (បើប្រៀបធៀបនឹងខែវិច្ឆិកា មានចំនួន**៣៥៤.០៦៧**នាក់) មានការកើនឡើងចំនួន **៩៧.៥៣៦**នាក់ ស្មើនឹង**២៧,៥៤%** ។ (**ឧបសម្ព័ន្ធទី១**)

### ខ.៣. យុទ្ធនាការ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ៖

- **ថ្នាក់ជាតិ៖**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** បានសហការជាមួយអង្គការដៃគូដូចជា៖ USAID, WINROCK, The Asia Foundation, UN-ACT, Terre des Hommes, IJM, IOM, APLE, Cambodia Acts...) ផលិតសម្ភារផ្សព្វផ្សាយអប់រំ និងទូរទស្សន៍ BTV ដែលបានសហការ ទូរទស្សន៍ PNN ផលិតជាខ្សែវីដេអូ បទយកការណ៍ ស្តីពីអំពើជួញដូរមនុស្ស និងការសម្តែងសិល្បៈចំរុះរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបញ្ជ្រាបការយល់ដឹងដល់អង្គពិធីទាំងមូល ក្នុងកម្មវិធីយុទ្ធនាការ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ ធ្នូ លើកទី១២ ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ **៣.០០០**អង្គ/នាក់ ជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានា ដែលមាននិវេសនដ្ឋាននៅកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា កម្មករ និយោជក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

- **ថ្នាក់ក្រោមជាតិ៖**

**លេខាធិការដ្ឋានរាជធានី-ខេត្ត និងមន្ទីរ អប់រំយុវជន និងកីឡាខេត្ត** បានសហការជាមួយអង្គការដៃគូ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៨ និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋប្រមាណ **៩.៨៨៤.៤២០**នាក់ (ស្រី **២៨៣.៧២០**នាក់)។

## ខ.៤. ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

❖ **ថ្នាក់រាជធានី ខេត្តៈ**

បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមប៉ុស្តិ៍វិទ្យុ សរុបចំនួន **៧៨៩**លើក ក្នុងនោះខេត្តៈ

- ខេត្តកោះកុង ចំនួន ២៨លើក
- ខេត្តសៀមរាប ចំនួន **៧៥៨**លើក
- ខេត្តព្រះវិហារ ចំនួន ០៣លើក។

❖ **អង្គការដៃគូៈ**

- **អង្គការ សាម៉ារីតាន់ភឺស** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ពលករចំណាកស្រុក ចំនួន**៧៨**នាក់ (ស្រី**៣៥**នាក់) ដែលបញ្ជូនត្រឡប់ពីព្រំដែន តាមច្រកដូង ខេត្តបាត់ដំបង។
- **អង្គការ CCPCR ខេត្តកោះកុង** បានសហការជាមួយសមត្ថកិច្ចធ្វើការផ្សព្វផ្សាយអំពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព សរុបចំនួន **១២**លើក មនុស្សចំនួន **៩០**នាក់ (ស្រី **៧៤**នាក់)។
- **អង្គការសេដាក ខេត្តសៀមរាប** សហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលកសិករឲ្យយល់ដឹងអំពីការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការងារធ្វើកសិកម្មធម្មជាតិជាលក្ខណៈគ្រួសារ នៅក្នុងស្រុកគោលដៅចំនួន០៧ (ស្រុកស្រីស្នំ វ៉ារិន សូទ្រនិគម ជីក្រែង អង្គរជុំ និងស្រុកពួក) មាន១១ឃុំ និង ៦១ភូមិ។

## ខ.៥. វិធានការបង្ការ ទប់ស្កាត់ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

### ខ.៥.១. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទៈ

សាលាខេត្ត នគរបាលជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត មន្ទីរចំណុះខេត្ត បានសហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្តៈ**
  - **កម្លាំងជំនាញអនុវត្ត** នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ, មណ្ឌលគីរី, ស្វាយរៀង, សៀមរាប, កែប, ឧត្តរមានជ័យ, បន្ទាយមានជ័យ, ក្រចេះ និងរតនគីរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីក្នុងហាងម៉ាស្សាខារ៉ាអូខេបានចំនួន **៥៦៥**គោលដៅ និងមានមនុស្សចំនួន **១,៨៣៣**នាក់ (ស្រី**១,៧៦៨**នាក់)។
  - គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦**គោលដៅ សរុបចំនួន **៧៥**គោលដៅ ទូទាំងរាជធានី-ខេត្ត។
  - ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន ៤០លើក ខេត្តអនុវត្តមានៈ ព្រះវិហារ, ឧត្តរមានជ័យ, ក្រចេះ, ស្ទឹងត្រែង, កំពង់ស្ពឺ និងព្រៃវែង។

- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖ កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧, ៨១៩, ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែន ៥៦លើក។

- អង្គការដៃគូ៖
  - **អង្គការម្លប់តាប៉ាង ខេត្តព្រះសីហនុ** ដើម្បីការពារសុវត្ថិភាព កុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បីចំនួន **១៤៣**នាក់ ផ្ទះសំណាក់ សណ្ឋាគារ **២៤**កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ **៧១**នាក់ បណ្តាញតាមសហគមន៍ **៦០**នាក់ ផ្នែកភ្នាក់ងារទេសចរណ៍ **០២**នាក់ សមាជិកបណ្តាញដែលជាបុគ្គលិកផ្ទះសំណាក់/សណ្ឋាគារ **៣៧៤**នាក់។

## ខ.៦. វិធានការប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់

### ខ.៦.១. វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេសសរុបចំនួន ៣៧១.៤៨៣នាក់ (ស្រី១៦១.០៦៦នាក់) អនីតិជន១០.៦៨៣នាក់(ស្រី៤.១៥៦នាក់) ក្នុងនោះស្របច្បាប់ចំនួន ២១០.០៦១នាក់(ស្រី ៩៥.២៤៨នាក់) អនីតិជន ១.៩៨៩នាក់(ស្រី ៩០៧នាក់) មិនស្របច្បាប់ចំនួន ១៦១.៤២២នាក់(ស្រី ៦៥.៨១៨នាក់) អនីតិជន ៨.៦៩៤នាក់ (ស្រី ៣.២៤៩នាក់) បើប្រៀបធៀបខែមុនកើនចំនួន ១.៣១៣នាក់ ស្មើ ០,៣៥%។

## ខ.៧. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈ ការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន **១៥១**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ចំនួន ០៩នាក់ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

# គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តច្បាប់**) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន ១៤/១១ករណី (បើប្រៀបធៀបនឹងខែមុន កើនឡើង ០៣ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៤នាក់(ស្រី ០៤នាក់) ជនសង្ស័យជាអនីតិជន ០៤នាក់ និងជនបរទេស ០១នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ៣០នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ១៦នាក់ អាយុ១៥-១៧ឆ្នាំ ០២នាក់ និងអាយុ១៨ឆ្នាំឡើង ១២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ១៥នាក់ និងប្រគល់ទៅគ្រួសារ ១៥នាក់)។

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០២/០៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់(ស្រី) ។ សង្គ្រោះជនរងគ្រោះចំនួន ០៨នាក់ អាយុ-១៥ឆ្នាំ ០២នាក់ អាយុ១៥-១៧ឆ្នាំ ០២នាក់ និង អាយុ១៨ឆ្នាំឡើង០៤នាក់(ប្រគល់ឲ្យសង្គមកិច្ច ០៧នាក់ និងឲ្យគ្រួសារ០១នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់មានគោលដៅ | ០១ | ០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ១១ |
| *សរុប* | *០២ ករណី* | *១២នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១២/០៨ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១២នាក់(ស្រី ០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ២២នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ១៤នាក់ អាយុ១៨ឆ្នាំឡើង ០៨នាក់ (ប្រគល់ទៅសង្គមកិច្ច ០៨នាក់ និងប្រគល់ទៅគ្រួសារ ១៤នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ញារកម្ម | ០១ | ០១ | |
| -ផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥. អនីតិជន៣ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥. អនីតិជន១ | អង់គ្លេស១ |
| *សរុប* | *១២ ករណី* | *១២ នាក់* | *០១នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

ឃ.១.១. ការទទួលជនសង្ស័យរងគ្រោះ

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន ១៣នាក់ (ស្រី ១២នាក់) ក្នុងនោះមកពី៖

- ប្រទេសចិន ចំនួន ០៦នាក់ (ស្រី ០៦នាក់)
- ប្រទេសវៀតណាម ចំនួន ០៣នាក់ (ស្រី ០៣នាក់)
- ប្រទេសសឹង្ហបុរី ចំនួន ០២នាក់ (ស្រី ០២នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន ០១នាក់ (ស្រី ០១នាក់)
- ប្រទេសឡាវ ចំនួន ០១នាក់។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តច្បាប់)**

បានទទួល និងសំភាសន៍ពលរដ្ឋខ្មែររងគ្រោះចំនួន **៤១**នាក់ (ស្រី ០៦នាក់) មកពីប្រទេសចិន **០៦**នាក់ និងប្រទេសសូម៉ាលី **៣៥**នាក់ តាមការសម្ភាសបានឲ្យដឹងថា អ្នកទាំងនោះទៅតាមរយៈមេខ្យល់**៣៦**នាក់ និងទៅដោយខ្លួនឯង**០៥**នាក់ ។ ក្នុងនោះមានៈ

- ប្រទេសសូម៉ាលី ចំនួន **៣៥**នាក់ (តាមរយៈមេខ្យល់ **៣០**នាក់ និងខ្លួនឯង **០៥**នាក់)
- ប្រទេសចិន ចំនួន **០៦**នាក់ (តាមរយៈមេខ្យល់)។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **៩១**លើក មនុស្ស ចំនួន **១.៥៦៧**នាក់ (ស្រី **៥០០**នាក់ កុមារ **១៩២**នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន **៥៨**នាក់
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន **១.៥០៧**នាក់
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន **០២**នាក់។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន **២៦**នាក់ (ប្រុស)។ មានដូចខាងក្រោម ៖

- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន **២៦**នាក់(ប្រុស) ជាករណីជួញដូរកម្លាំងពលកម្ម។

### ឃ.២. <u>ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស</u>

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិម្បទាចំនួន **៥៨**នាក់ (ស្រី **១១**នាក់) កុមារ **១៦**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទាដល់ជនរងគ្រោះ និងងាយរងគ្រោះ ចំនួន **៥៨**នាក់ (ស្រី **១១**នាក់) កុមារ **១៦**នាក់ ក្នុងនោះករណីជួញដូរកម្លាំងពលកម្ម **២៦**នាក់ និងងាយរងគ្រោះ **៣២**នាក់ ទៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ អង្គការតំណក់ទឹក អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងអង្គការកល្យាណមិត្ត ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗ ទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។

### ឃ.៣. <u>ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ</u>

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៥នាក់ (ករណីរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិចិន) អោយត្រឡប់ទៅសហគមន៍វិញ។

**របាយការណ៍ពីស្ថានភាព៖**

- **ស្នងការដ្ឋានរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ**

**ស្នងការដ្ឋាននគរបាលខេត្ត** បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាត់បញ្ជូនត្រឡប់មកកម្ពុជាវិញ បានចំនួន **៥៨**លើក មនុស្សចំនួន **១.២៦១**នាក់ (ស្រី **៣៩៤**នាក់) អនីតិជន **១៦៥**នាក់ ក្នុងនោះមាន៖

+ **តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ៖**

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ចំនួន **៤៨**លើក មនុស្សចំនួន **១.២១២**នាក់ (ស្រី **៣៨៣**នាក់) អនីតិជន **១៦០**នាក់។
- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង តាមច្រកអន្តរជាតិដូង ចំនួន **០៩**លើក មនុស្សចំនួន **៤៥**នាក់ (ស្រី **០៩**នាក់) អនីតិជន **០៣**នាក់។

+ **តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម៖**

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀងចំនួន **០១**លើក មនុស្សចំនួន **០៤**នាក់ (ស្រី **០២**នាក់) អនីតិជន **០២**នាក់។

- **អគ្គបញ្ជាការដ្ឋានទីចាត់ការ ការងារព្រំដែន នៃក្រសួងការពារជាតិ**

ដោយឡែក **អគ្គបញ្ជាការដ្ឋានទីចាត់ការ ការងារព្រំដែន** បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ចំនួន **១.២២២**នាក់ (ស្រី **៣៦៨**នាក់) អនីតិជន **១៣៩**នាក់ ក្នុងនោះមាន៖

- ច្រកអន្តរជាតិប៉ោយប៉ែត ចំនួន **១.១៦២**នាក់ (ស្រី **៣៥១**នាក់) អនីតិជន **១៣៩**នាក់
- ច្រកអន្តរជាតិដូង ចំនួន **៦០**នាក់ (ស្រី **១៧**នាក់)

**ការគ្រប់គ្រងជនបរទេស៖**

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសដែលល្មើសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១. **ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់:** ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន **៥៥**លើក មនុស្សចំនួន **៣១២**នាក់ មាន **២២**សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋាន ចំនួន **២៦**លើក មនុស្សចំនួន **២៧៧**នាក់ មាន **០៨**សញ្ជាតិ
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន **២៩**លើក មនុស្សចំនួន **៣៥**នាក់ **១៤**សញ្ជាតិ។

២. **ករណីស្នាក់នៅខុសច្បាប់**

- គ្មានឯកសារគ្រប់គ្រាន់ **០២**លើក មនុស្ស **០២**នាក់ មាន **០២**សញ្ជាតិ វៀតណាម និងនីហ្សេរីយ៉ា
- គ្មានលិខិតឆ្លងដែន **០១**លើក មនុស្សចំនួន **០១**នាក់ សញ្ជាតិចិន។

៣. **ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី**

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍សរុបចំនួន **៧៤**គ្រួសារ មនុស្សចំនួន **២២៨**នាក់ (ស្រី **១០១**នាក់) សញ្ជាតិវៀតណាម ក្នុងនោះដកហូតឯកសារ បានចំនួន **១៧៤**ឯកសារ។ ≈4BT tha h

## III. ការលើកកម្ពស់សមត្ថភាព

### ក. ក្នុងប្រទេស

#### ក.១. ការងារបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័នអនុវត្ត និងលេខាធិការដ្ឋាន រាជធានី-ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន **០៥**វគ្គ មានសិក្ខាកាមចូលរួមចំនួន **១៨៧**នាក់ ក្នុងនោះមានស្ត្រី **២៤**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ ៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការអនុវត្តច្បាប់ បានចូលរួមជាគ្រូឧទ្ទេស និងចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ការសិក្សា ក្នុងវគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្គាសកំណត់អត្តសញ្ញាណជនរងគ្រោះ នៅខេត្តស្វាយរៀង។<br>- បានសហការជាមួយអង្គការ Childfund Cambodia រៀបចំវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ ក្នុងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ នៅខេត្តស្វាយរៀង។ | ០២ | ៦៧ | ២៤ |
| ២ | **ខេត្តព្រៃវែង** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលស្តីពីអនុក្រឹត្យលេខ ១០៩ និងប្រកាសស្តីពីការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ ដល់ថ្នាក់ស្រុក និងឃុំ។ | ០៣ | ១២០ | |
| | សរុប | **០៥** | **១៨៧** | **២៤** |

#### ក.២. សិក្ខាសាលា

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (គ.ជ.ប.ជ) សហការជាមួយអង្គការ (APLE) រៀបចំសិក្ខាសាលា ស្តីអំពីការបង្ការ និងការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារប្រព្រឹត្តដោយទេសចរ និងអ្នកដំណើរ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ សិក្ខាកាមចូលរួមចំនួន **៧០**នាក់ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ភ្នំពេញ។
- **ខេត្តឧត្តរមានជ័យ** ការិយាល័យជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ការងារ នៅសាលប្រជុំកាកបាទក្រហមកម្ពុជាខេត្ត អ្នកចូលរួម **១២៣**នាក់ (ស្រី **១៤**នាក់)។
- **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សហការជាមួយអង្គការ APLE បានសម្របសម្រួលរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី បទដ្ឋាននៃការអនុវត្តបែបកុមារមេត្រី ដើម្បីការពារជនរងគ្រោះនៃអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទ សិក្ខាកាមចំនួន **៦៥**នាក់ (ស្រី **១៦**នាក់)។ ក43T tha-n

ក.៣. ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៤៥**លើក មានអ្នកចូលរួមសរុប ៣.០២៧នាក់ (ស្រី ១.៩៩៤នាក់) ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន **២៦**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **១៩**លើក។ (ឧបសម្ព័ន្ធទី២)

## ខ. ក្រៅប្រទេស និងថ្នាក់អន្តរជាតិ

### ខ.១. កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ជាអន្តរជាតិ

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ត្រូវបានជ្រើសតាំងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំកំពូល ដើម្បីអនុម័តកត្តិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងម៉ារ៉ាគិច ប្រទេសម៉ារ៉ុក។ អ្នកចូលរួមក្នុងកិច្ចប្រជុំ មានប្រមាណជាង២.០០០នាក់ ជាថ្នាក់ដឹកនាំប្រទេស និងតំណាងមកពីជាង២០០ប្រទេសជុំវិញពិភពលោក។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**

  នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់មន្ត្រី០១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទលើស្ត្រី និងកុមារ លើកទី១ នៅប្រទេសសិង្ហបុរី។

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។

- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូរត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋាន

គតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមករា ឆ្នាំ ២០១៩

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ...........ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី............ខែ...........ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"**ដើម្បីជូនជ្រាប**"

-ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈ ខែធ្នូ ឆ្នាំ២០១៨**

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 166 លើក | 12,319 នាក់ | 6,757 នាក់ |
| 2 | ខេត្តកណ្ដាល | វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 452 លើក | 34,644 នាក់ | 19,425 នាក់ |
| | | ផ្សព្វផ្សាយច្បាប់ ស្ដីពីការការប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស និងបញ្ជ្រាបតាមកិច្ចប្រជុំនានាដល់អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក និងមន្ទីរអប់រំយុវជន និងកីឡា | 95 លើក | 5,001 នាក់ | 2,488 នាក់ |
| 3 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្ដីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 573 លើក | 39,345 នាក់ | 18,533 នាក់ |
| | | វេទិកាសាធារណៈ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | | 264 លើក | 10,151 នាក់ | 5,379 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 126 លើក | 4,558 នាក់ | 2,317 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅតាមវិទ្យាល័យ អនុវិទ្យាល័យទាំង២០ ទូទាំងខេត្តពោធិ៍សាត់ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 356 លើក | 34,065 នាក់ | 19,018 នាក់ |
| 5 | ខេត្តសៀមរាប | ផ្សព្វផ្សាយច្បាប់ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | មន្ទីរអប់រំ មន្ទីរកិច្ចការនារី ស្នងការដ្ឋាននគរបាលខេត្ត និងរដ្ឋបាលស្រុក | 73 លើក | 4,259 នាក់ | 2,432 នាក់ |
| | | វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 259 លើក | 17,512 នាក់ | 7,357 នាក់ |
| 6 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ដីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 366 លើក | 17,352 នាក់ | 9,686 នាក់ |
| | | ផ្សព្វផ្សាយ ស្ដីពីអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបការយល់ដឹងតាមរយៈកិច្ចប្រជុំនានា ដល់ប្រជាពលរដ្ឋ កម្មករនិយោជិត និងយុវជន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំខេត្ត មន្ទីរការងារខេត្ត | 22 លើក | 568 នាក់ | 256 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តកំពង់ឆ្នាំង | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងបញ្ជ្រាប ច្បាប់ស្តីពីការជួញដូរមនុស្ស ដល់ ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 436 លើក | 34,067 នាក់ | 19,754 នាក់ |
| 7 | ខេត្តកំពង់ចាម | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការ អនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1,155 លើក | 125,319 នាក់ | 67,972 នាក់ |
| | | ផ្សព្វផ្សាយច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងអនុក្រឹត្យលេខ ១៨៣ ព្រមទាំងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ជាមួយជនបរទេស។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំខេត្ត មន្ទីរការងារខេត្ត | 2,590 លើក | 25,261 នាក់ | 13,386 នាក់ |
| | | ផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 973 លើក | 54,333 នាក់ | 30,755 នាក់ |
| 8 | ខេត្តព្រះសីហនុ | ផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរកិច្ចការនារីខេត្ត | 15 លើក | 860 នាក់ | 358 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | ក្រុមការងារគ.ខ.ប.ជខេត្ត និងអាជ្ញាធរក្រុង/ស្រុក | 3 លើក | 212 នាក់ | 76 នាក់ |
| 9 | ខេត្តព្រៃវែង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 600 នាក់ | 450 នាក់ |
| 10 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់ ដល់កងកម្លាំងមន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 19 លើក | 7,069 នាក់ | 3,672 នាក់ |
| 11 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត។ | ក្រុមការងារអធិការនគរបាលក្រុង ស្រុក | 43 លើក | 1,610 នាក់ | 704 នាក់ |
| 12 | ខេត្តស្វាយរៀង | ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ តាមរយៈកិច្ចប្រជុំផ្សេងៗ | ស្នងការដ្ឋាននគរបាលខេត្ត | 12 លើក | 28 នាក់ | 24 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 347 លើក | 17,541 នាក់ | 9,667 នាក់ |
| 13 | ខេត្តរតនគិរី | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 9 លើក | 434 នាក់ | 212 នាក់ |
| 14 | ខេត្តតាកែវ | ផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរសង្គមកិច្ចខេត្ត | 30 លើក | 1,075 នាក់ | 870 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 15 | ខេត្តក្រចេះ | ផ្សព្វផ្សាយស្តីពីយុត្តិធម៌អនីតិជន ជូនដល់ប្រជាពលរដ្ឋនៅស្រុកស្នួល | មន្ទីរសង្គមកិច្ចខេត្ត | 5 លើក | 159 នាក់ | 87 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរសង្គមកិច្ចខេត្ត | 1 លើក | 43 នាក់ | 37 នាក់ |
| 16 | ខេត្តប៉ៃលិន | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 40 លើក | 1,456 នាក់ | 741 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។ | | 45 លើក | 1,762 នាក់ | 953 នាក់ |

សកម្មភាពសរុបចំនួន: 8,479 លើក

មនុស្សសរុបចំនួន: 451,603 នាក់

ស្រីសរុបចំនួន : 243,366 នាក់

# ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៤៥លើក) មនុស្សចំនួន ៣.០២៧នាក់ (ស្រី ១.៩៩៤នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន ២៦លើក មនុស្សចំនួន ២៣៥នាក់ (ស្រី ២៤នាក់)<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ៖<br>– បានដឹកនាំកិច្ចប្រជុំពិភាក្សាការងាររួមគ្នាផ្តល់ធាតុចូលទៅលើកម្រងសំណួរលើកទី១២ របស់អង្គការសហប្រជាជាតិសម្រាប់រដ្ឋាភិបាល ស្តីពីប្រជាជន និងការអភិវឌ្ឍន៍ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម **ជីវ ផល្លី** អគ្គលេខាធិការរង និងក្រុមការងារទេសន្តប្រវេសន៍ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>– បានដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពី ការងារ និងបែបបទរដ្ឋបាល របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន ៧២នាក់ (ស្រី១១នាក់)។<br>– បានដឹកនាំកិច្ចប្រជុំ ក្រុមការងារចម្រុះប្រចាំការទទួលពលករ ពលការនីកម្ពុជា ដែលបានបញ្ជូនមកពីប្រទេសថៃ តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ អ្នកចូលរួមចំនួន ២៥នាក់ ស្រី០៥នាក់។<br>– បានអញ្ជើញជាអធិបតី ក្នុងពិធីអបអរសាទរ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៨ លើកទី១២ នៅខេត្តសៀមរាប។<br>– បានចុះសិក្សាដោះស្រាយរកទីតាំងបណ្តោះអាសន្នសម្រាប់ដំណើរការនៃក្រុមការងារទទួលពលករ នៅមណ្ឌលក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ<br>– បានដឹកនាំកិច្ចប្រជុំ ស្តីពីវឌ្ឍភាពការងារទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៨ របស់ក្រុមនីមួយៗ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ៣៧នាក់ ស្រី០៤នាក់។<br>– បានអញ្ជើញចូលរួមកិច្ចប្រជុំសំណេះសំណាល ជាមួយសមាគមន សហគ្រិនស្ត្រីកម្ពុជា និងសមាជិក ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកប្រធាន អនុប្រធានលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>– បានអញ្ជើញចូលរួមប្រជុំ ស្តីពីការធ្វើសមាហរណកម្មស្ត្រី និងទារក (ករណីពពោះជំនួស) ឲ្យវិលត្រឡប់ទៅសហគមន៍វិញ នៅការិយាល័យអង្គការ AIM។<br>– បានដឹកនាំកិច្ចប្រជុំ ស្តីពីការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ៣៧នាក់ (ស្រី០៣នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |

| | |
|---|---|
| | – បានជួបប្រជុំជាមួយឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធាន អនុប្រធានលេខាធិការដ្ឋាន និងប្រធាន អនុប្រធានក្រុមកិច្ចការទាំង៦ ក្រោមអធិបតីភាព លោកជំទាវ **ជួញ សុផៃ** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ពិភាក្សា និងពិនិត្យលើសេចក្តីប្រកាសព័ត៌មាន ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>– បានអញ្ជើញចូលរួមប្រជុំ ស្តីពីការពិនិត្យលើបច្ចុប្បន្នភាព នៃការប្រើប្រាស់ ឧបករណ៍តាមដានអនុវត្តអនុសញ្ញា CEDAW ក្នុងគោលបំណងបង្កើនគុណភាព នៃការប្រមូលទិន្នន័យ និងព័ត៌មាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រៀបចំដោយក្រសួងកិច្ចការនារី នៅភោជនីយដ្ឋានទន្លេបាសាក់២។<br>– បានអញ្ជើញចូលរួមប្រជុំជាមួយ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង និងក្រុមការងារទេសន្តរប្រវេសន៍ លើកម្រងសំណួរលើកទី១២ របស់អង្គការសហប្រជាជាតិ សម្រាប់រដ្ឋាភិបាល ស្តីពីប្រជាជន និងការអភិវឌ្ឍ ក្រោមអធិបតីភាព ឯកឧត្តម **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ។<br>– បានអញ្ជើញចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារក្នុងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ រៀបចំដោយអង្គការ ឆាលហ្វាន នៅខេត្តស្វាយរៀង។<br>– បានអញ្ជើញចូលរួមប្រជុំការងារយេនឌ័រ នៅខេត្តសៀមរាប រៀបចំដោយ ក្រសួងកិច្ចការនារី។<br>**១ . <u>ក្រុមជំនួយការបង្ការ ទប់ស្កាត់:</u>**<br>– លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួមប្រជុំ ស្តីពីការបង្កើតក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា។<br>– ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន វ៉ូ** អគ្គលេខាធិការរង បានចូលរួមក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារក្នុងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។<br>**២. <u>ក្រុមការងារអនុវត្តច្បាប់</u>**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គលេខាធិការរង និងលោកប្រធាន ក្រុមជំនួយកិច្ចការបានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស ដែលពាក់ព័ន្ធនឹងករណីរំលោភសេពសន្ថវៈលើស្ត្រី និងក្មេងស្រី ដើម្បីឆ្លើយតបចំពោះសំណើរបស់គណៈកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិ។<br>**៣. <u>ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ:</u>**<br>- បានចូលរួមសន្និសីទថ្នាក់តំបន់ ស្តីពីសន្និសីទថ្នាក់តំបន់ឆ្ពោះទៅអនុវត្តយុទ្ធសាស្ត្រ INSPIRE ទាំងប្រាំពីរ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>- បានធ្វើសមាហរណកម្មស្រីរកស៊ីពពោះជំនួសចំនួន០១នាក់ ទៅខេត្តកំពង់ឆ្នាំងវិញ។ |

- លោកប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារក្នុងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ ក្រោមអធិបតីភាពលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ ។

**៤. ក្រុមជំនួយកិច្ចការយុត្តិធម៌:**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរង
  - បានចូលរួមប្រជុំគណៈកម្មការចងក្រងសន្ទានុក្រមបច្ចេកសព្ទ សម្រាប់វិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងពន្ធនាគារ នៅបណ្ឌិត្យសភានគរបាលកម្ពុជា ដែលមានសមាសភាពចូលរួមពីមន្ត្រីជាន់ខ្ពស់ផ្ទៃក្នុងក្រសួងមហាផ្ទៃ។
  - បានអញ្ជើញចូលរួមបើកសិក្ខាសាលា ស្តីពីការចូលរួមចំណែករបស់សហគមន៍ ក្នុងការលើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ធ្វើឡើងក្នុងគោលបំណងបង្ហាញពី លទ្ធផល និងបញ្ហាប្រឈមក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្ម បង្ហាញពីការចូលរួមរបស់យុវជន និងវេបសាយ បង្ហាញពីការឆ្លុះបញ្ចាំងពីគម្រោង និងសេចក្តីសន្និដ្ឋាន ដែលមានសមាសភាពចូលរួមពីភាគីពាក់ព័ន្ធ ប្រមាណ៦០នាក់ ដើម្បីនិរន្តរភាពក្រោយបញ្ចប់អាណត្តិរបស់អង្គការ GVC នៅសណ្ឋាគារ រី ខេត្តសៀមរាប។
  - បានដឹកនាំកិច្ចប្រជុំ ស្តីពីការផ្តល់កិច្ចសំភាស ដល់អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) ក្រោមកិច្ចសហការជាមួយ វិទ្យាស្ថាន Overseas Development Institute (ODI) និងជំនួយបច្ចេកទេសរបស់មូលនិធិអង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UN WOMEN) នឹងធ្វើការស្រាវជ្រាវមួយ ដើម្បីពិនិត្យមើលទៅលើស្ថានភាពនៃការជួញដូរកុមារ និងស្ត្រីកម្ពុជា ទៅក្នុងប្រទេសថៃ និងការពិនិត្យមើលទៅលើប្រសិទ្ធភាពនៃការឆ្លើយតបអំពើជួញដូរមនុស្ស ជាពិសេសកិច្ចអន្តរាគមន៍នានា ដែលពាក់ព័ន្ធការបង្ការទប់ស្កាត់ និងការធ្វើសមាហរណកម្មជនរងគ្រោះ (ដែលមានសមាភាពចូលរួម ០៤នាក់ ស្រី០១នាក់)។

**៥. ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ:**

- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង
  - បានធ្វើការចូលជួបជាមួយ លោកស្រី Jam ប្រធានអង្គការ STELLA MARIS អំពីការស្នើសុំកិច្ចសហការលិខិតបញ្ជាក់ថា អនុញ្ញាតឲ្យអង្គការការីតាស់សម្ភាសន៍អ្នកមកពីសូម៉ាលី ចំនួន១៦នាក់។
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការពិនិត្យលើបច្ចុប្បន្នភាពនៃការប្រើប្រាស់ឧបករណ៍តាមដានការអនុវត្តអនុសញ្ញា CEDAW នៅភោជនីដ្ឋានទន្លេបាសាក់២។

**៦. ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:**

- លោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ និងមន្ត្រីចំនួន០១រូប បានចូលរួមសិក្ខាសាលា ផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ឆ្នាំ ២០១៩-២០២៣ និងគោលការណ៍ណែនាំ ស្តីពីការដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍ រៀបចំឡើងដោយអង្គការ ILO Traingle នៅសណ្ឋាគារភ្នំពេញ។

| | |
|---|---|
| | **៧. លេខាធិការដ្ឋាន គ.ខ.ប.ជ៖**<br>❖ ការងាររដ្ឋបាលមានដូចខាងក្រោម:<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (២០ច្បាប់) លិខិតចូល (១១ច្បាប់)<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន៖ លិខិតចេញ (២០ច្បាប់) លិខិតចូល២៤ច្បាប់)<br>- បានធ្វើរបាយការណ៍ប្រចាំសប្ដាហ៍ និងប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ប្រចាំខែ និងត្រីមាសទី៤)។<br>- បានរៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- បានបញ្ជូនរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅកាន់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។<br>- បានចងក្រង ព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដាក់ចូលក្នុងបណ្ណាសារវីគី និងគ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- បានស្រាវជ្រាវព័ត៌មានពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន ដែលចុះផ្សាយ នៅក្នុងបណ្ដាញសង្គម និងគេហទំព័រនានា។<br>- បានស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី និងរៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ នៅរៀងរាល់កិច្ចប្រជុំ។<br>- បានបូកសរុបរបាយការណ៍ប្រចាំសប្ដាហ៍ និងខែ ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៩លើក អ្នកចូលរួមសរុបចំនួន ១.៥០៦នាក់ (ស្រី ១.០៧៧នាក់)** | |
| **ខេត្តកណ្ដាល** | - ក្រុមការងារថ្នាក់ក្រុង-ស្រុកទាំង១១ បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន ០៧លើក អ្នកចូលរួមចំនួន ១៣៥នាក់ ស្រី ៥៨នាក់។ |
| **ខេត្តព្រៃវែង** | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាពសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។<br>- បានចាត់មន្ត្រីលេខាធិការដ្ឋាន ចូលរួមជាវាគ្មិនវេទិកាចំណាកស្រុកដោយសុវត្ថិភាព និងការងារ ដែលរៀបចំដោយអង្គការសាក្រេដ មានអ្នកចូលរួម ១.០៣០នាក់ ស្រី ៧៧២នាក់។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបដឹកនាំកិច្ចប្រជុំប្រចាំខែធ្នូ ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ២៨នាក់ ស្រី ០៧នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - បានចូលរួមប្រជុំ គ ក ស ក ប្រចាំខែធ្នូ អ្នកចូលរួមចំនួន ២៥នាក់ ស្រី ១១នាក់ នៅសាលាខេត្ត។ |

| | |
|---|---|
| **ខេត្តក្រចេះ** | - លេខាធិការដ្ឋាន (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំជាមួយក្រុមការងារទាំង៦ របស់គណៈកម្មការអន្តរមន្ទីរ និងក្រុមលេខាធិការដ្ឋានខេត្ត ស្តីពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែធ្នូ ២០១៨ មានអ្នកចូលរួម ៦៨នាក់ ស្រី ៤៥នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន (គ.ខ.ប.ជ) បានដឹកនាំកិច្ចប្រជុំប្រចាំខែធ្នូ ឆ្នាំ២០១៨ និងបានរៀបចំផ្លាស់ប្តូរសមាសភាពក្រុមទាំង៦ ដោយសមាជិកខ្លះចូលនិវត្តន៍ និងខ្លះទៀតត្រូវផ្ទេរចេញ។ |
| **ខេត្តកំពង់ធំ** | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។<br>- បានចូលរួមបានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ នៅសាលាស្រុកសន្ទុក មានអ្នកចូលរួម ២២០នាក់ ស្រី ១៨៤នាក់។ |
| **ខេត្តកំពង់ស្ពឺ** | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។ |
| **ខេត្តបន្ទាយមានជ័យ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ និងចូលរួមពិភាក្សាស្តីពីរបៀបរបបការងារទទួលពលករ នៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែតថ្មី ក្រោមអធិបតីភាពលោកជំទាវ ជូ **ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| **ខេត្តប៉ៃលិន** | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។<br>- រដ្ឋបាលក្រុងប៉ៃលិន បានរៀបចំកិច្ចប្រជុំប្រចាំខែ និងផ្សព្វផ្សាយអំពីការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកដោយខុសច្បាប់។ |